NGO-CEDAW

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បី
អនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ

# អនុសញ្ញា

# ស្តីពី
# ការលុបបំបាត់រាល់ទម្រង់
# នៃការរើសអើងនឹងនារីភេទ

ឧបត្ថម្ភដោយៈ
កម្មវិធីជំនួយអូស្ត្រាលី

# អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងនឹងនារីភេទ ៖ សេចក្តីសង្ខេបគន្លឹះសំខាន់ៗនៃមាត្រានីមួយៗ

### មាត្រា ១ ៖និយមន័យនៃការរើសអើង

"ការបែងចែក ការផាត់ចេញការរឹតត្បិតផ្អែកលើភេទដែលមានបំណង ឬអនុភាពធ្វើឲ្យមោឃៈភាព ឬខូចខាតនូវការទទួលស្គាល់ការអាស្រ័យផល និងការប្រើប្រាស់ដោយស្ត្រីទៅលើសិទ្ធិទាំងអស់នៅក្នុងវិស័យនយោបាយ វប្បធម៌ សង្គម និសេដ្ឋកិច្ចគឺជាការរើសអើង "

### មាត្រា ២៖ ភាតព្វកិច្ចរបស់រដ្ឋភាគី

រដ្ឋភាគីត្រូវតែលុបបំបាត់ការរើសអើងនៅក្នុងច្បាប់ គោលនយោបាយ និងការអនុវត្តទាំងឡាយនៅទូទាំងប្រទេស ។

### មាត្រា ៣៖ សមភាព

រដ្ឋភាគីត្រូវប្រកាន់យកវិធានការនានា ដើម្បីរក្សានូវសមភាពស្ត្រីលើគ្រប់វិស័យនៅក្នុងវិស័យនយោបាយ សង្គម សេដ្ឋកិច្ច និង វប្បធម៌។

### មាត្រា ៤៖ វិធានការវិសេសបណ្តោះអាសន្ន

ប្រសិនបើចាំបាច់ក្នុងការពន្លឿនសមភាពរបស់ស្ត្រី រដ្ឋភាគីត្រូវបានអនុញ្ញាតិអោយអនុវត្តវិធានការវិសេសបណ្តោះអាសន្ន ។

### មាត្រា ៥៖ តួនាទីភេទ និងផ្នត់គំនិតសង្គម

រដ្ឋភាគីត្រូវតែលុបបំបាត់នូវការអនុវត្តបែបវប្បធម៌ និងប្រពៃណីទាំងឡាយណាដែលមានលក្ខណៈរើសអើង ។

### មាត្រា ៦៖ ការជួញដូរ

រដ្ឋភាគីត្រូវតែចាត់នូវរាល់វិធានការសមស្របទាំងអស់ដើម្បី បង្ក្រាបការជួញដូរស្ត្រីនិងអាជីវកម្មពេស្យាចារលើស្ត្រី ។

### មាត្រា ៧៖ នយោបាយ និងជីវភាពសាធារណៈ

ស្ត្រីត្រូវតែមានសិទ្ធិស្មើគ្នាក្នុងការបោះឆ្នោតធ្វើប្រជាមតិជាសាធារណៈ និងចូលរួមនៅក្នុងសង្គមស៊ីវិល ។

### មាត្រា ៨៖ ភាពជាតំណាងអោយរដ្ឋាភិបាល

ស្ត្រីត្រូវតែទទួលការអនុញ្ញាតអោយធ្វើការ និងធ្វើជាតំណាងអោយរដ្ឋាភិបាលនៅថ្នាក់អន្តរជាតិ។

## មាត្រា៩៖ សញ្ជាតិ

ស្ត្រីមានសិទ្ធិស្មើបុរសក្នុងការទទួល រក្សាទុក រឺផ្លាស់ប្តូរសញ្ជាតិរបស់ពួកគេ និងកូនៗផងដែរ ។

## មាត្រា ១០៖ ការអប់រំ

ស្ត្រីមានសិទ្ធិស្មើនឹងបុរសនៅក្នុងវិស័យអប់រំ ។

## មាត្រា ១១៖ ការងារ

ស្ត្រីមានសិទ្ធិស្មើបុរសនៅក្នុងវិស័យការងារ ( ប្រាក់កម្រៃស្មើគ្នា លក្ខខណ្ឌសុខភាពការងារដូចគ្នា ជាដើម។ល។ )

## មាត្រា ១២៖ សុខភាព

ស្ត្រីមានសិទ្ធិស្មើបុរសក្នុងការទទួលបានការថែទាំសុខភាព រួមមានសេវាកម្មផ្នែកសុខភាពបន្តពូជផង ។

## មាត្រា ១៣៖ សិទ្ធិសេដ្ឋកិច្ច និងសង្គម

ស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការទទួលបានផលប្រយោជន៍ផ្សេងៗពីគ្រួសារ កម្ចីហិរញ្ញវត្ថុ និងការចូលរួមនៅក្នុងសកម្មភាពកំសាន្តនានា ។

## មាត្រា ១៤៖ ស្ត្រីជនបទ

ស្ត្រីជនបទត្រូវតែមានសិទ្ធិ ទទួលបានការរស់នៅសមរម្យ ការចូលរួមនៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ ហើយទទួលបាននូវសេវាថែទាំសុខភាព និងអប់រំ ។

## មាត្រា ១៥៖ សមភាពនៅចំពោះមុខច្បាប់

ស្ត្រីនិងបុរសត្រូវតែទទួលបានសមភាពនៅចំពោះមុខច្បាប់ មានសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ទ្រព្យសម្បត្តិ និង ជ្រើសរើសទីកន្លែងសម្រាប់លំនៅដ្ឋាន ។

## មាត្រា ១៦ អាពាហ៍ពិពាហ៍ និងគ្រួសារ

ស្ត្រីមានសិទ្ធិស្មើបុរស នៅក្នុងការរៀបអាពាហ៍ពិពាហ៍ រួមទាំងការធ្វើផែនការគ្រួសារផង ។

## មាត្រា ១៧ -ដល់ ២៤៖

សំដៅដល់មុខងារ និងតួនាទីរបស់គណៈកម្មាធិការទទួលបន្ទុកលើអនុសញ្ញា ស៊ី ដវ និងនិតិវិធីនៃការរាយការណ៍ ។

## មាត្រា ២៥ ដល់ ៣០ ៖

សំដៅដល់កិច្ចការរដ្ឋបាលនៃអនុសញ្ញា ស៊ី ដវ ។

# អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងនឹងនារីភេទ

អនុម័ត និងបើកឲ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន
និងឲ្យចូលជាសមាជិកតាមសេចក្តីសម្រេចលេខ ៣៤១៨០
ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ របស់មហាសន្និបាទអង្គការសហប្រជាជាតិ
ចូលជាធរមាននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៨១ ស្របតាមបទបញ្ញត្តិមាត្រា ២៧(១)
ចូលជាធរមានក្នុងប្រទេសកម្ពុជានៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩២

## រដ្ឋភាគីនៃអនុសញ្ញានេះ

- កត់សម្គាល់ឃើញថា ធម្មនុញ្ញសហប្រជាជាតិអះអាងជាថ្មីនូវជំនឿលើសិទ្ធិមូលដ្ឋានរបស់មនុស្ស លើសេចក្តីថ្លៃថ្នូរ និងតម្លៃមនុស្ស និងលើសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី។
- កត់សម្គាល់ឃើញថា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បញ្ជាក់នូវគោលការណ៍មិនរើសអើង និងបានប្រកាសថា មនុស្សគ្រប់រូបកើតមកមានសេរីភាពនិងមានសមភាពក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិ ហើយថា មនុស្សគ្រប់រូបត្រូវទទួលបានសិទ្ធិសេរីភាពទាំងអស់ដែលមានចែងក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកណាមួយរួមទាំងការបែងចែងខាងផ្លូវភេទផង។
- កត់សម្គាល់ឃើញថា រដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស មានកាតព្វកិច្ចធានាសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រីក្នុងការអាស្រ័យផលសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ពលរដ្ឋ និងនយោបាយ។
- យល់ឃើញថា អនុសញ្ញាអន្តរជាតិដែលបានអនុម័តក្រោមកិច្ចឧបត្ថមរបស់អង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា ក្នុងការលើកម្ពស់សមភាពនៃសិទ្ធិបុរសនិងស្ត្រី។
- កត់សម្គាល់ឃើញថា សេចក្តីសម្រេច សេចក្តីប្រកាស និងអនុសាសន៍នានាដែលបានអនុម័តដោយអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា ក្នុងគោលបំណងលើកម្ពស់សមភាពនៃសិទ្ធិបុរសនិងស្ត្រី។
- មានកង្វល់ថា ទោះបីមានលិខិតុបករណ៍ទាំងនេះហើយក្តី ក៏ការរើសអើងដែលកាន់តែរីករាលដាល ប្រឆាំងនឹងនារីភេទ នៅតែបន្តកើតមាន។
- រំលឹកឡើងវិញថា ការរើសអើងប្រឆាំងនឹងនារីភេទ រំលោភលើគោលការណ៍សមភាពនៃសិទ្ធិ និងការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាឧបសគ្គដល់ការចូលរួមរបស់ស្ត្រីក្នុងល័ក្ខខ័ណ្ឌស្មើភាពគ្នាជាមួយបុរសក្នុងជីវភាពនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌នៃប្រទេសរបស់ខ្លួន ធ្វើឲ្យរាំងស្ទះដល់ការរីកចម្រើននៃភាពសម្បូររុងរឿងរបស់សង្គម និងគ្រួសារ ហើយបង្ករការលំបាកកាន់តែខ្លាំងដល់ការអភិវឌ្ឍន៍នៃសក្តានុភាពរបស់ស្ត្រីក្នុងការបម្រើប្រទេសរបស់ខ្លួន និងមនុស្សជាតិ។
- មានកង្វល់ថា ក្នុងស្ថានភាពក្រីក្រ ស្ត្រីភេទបានទទួលតិចបំផុតនូវម្ហូបអាហារ សេវាសុខាភិបាល

ការអប់រំ ការបណ្តុះបណ្តាល និងឱកាសរកការងារធ្វើ ព្រមទាំងសេចក្តីត្រូវការដទៃទៀត។

- ជឿជាក់ថា ការបង្កើតប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិថ្មី ផ្អែកលើមូលដ្ឋានសមភាពនិងយុត្តិធម៌ និងរួមចំនែកយ៉ាងសំខាន់ដល់ការលើកម្ពស់សមភាពរវាងបុរសនិងស្ត្រី។
- គូសបញ្ជាក់ថា ការលុបបំបាត់ចោលរបបអាប៉ាថេត គ្រប់ទម្រង់ពូជសាសន៍និយម ការរើសអើងពូជសាសន៍ អាណានិគមនិយម អាណានិគមនិយមបែបថ្មី ការឈ្លានពាន ការកាន់កាប់និងការជិះជាន់ដោយបរទេស និងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ គឺជាការចាំបាច់ដល់ការអាស្រ័យផលពេញលេញពីសិទ្ធិរបស់បុរសនិងស្ត្រី។
- អះអាងថា ការពង្រឹងសន្តិភាព និងសន្តិសុខអន្តរជាតិ ការបន្ធូរភាពតានតឹងអន្តរជាតិសហប្រតិបត្តិការទៅវិញទៅមករវាងរដ្ឋទាំងអស់ ដោយមិនគិតដល់ប្រព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចរបស់រដ្ឋទាំងនោះ ការដកហូតអាវុធជាទូទៅនិងទាំងស្រុង ជាពិសេសការដកហូតអាវុធនុយក្លេអ៊ែរក្រោមការត្រួតពិនិត្យហ្មត់ចត់ និងដោយប្រសិទ្ធិភាពពីអន្តរជាតិ ការអះអាងនូវគោលការណ៍យុត្តិធម៌ សមភាព និងអត្ថប្រយោជន៍ទៅវិញទៅមក ក្នុងទំនាក់ទំនងរវាងប្រទេសទាំងឡាយ និងការសម្រេចបាននូវសិទ្ធិស្វ័យសម្រេច ឯករាជ្យភាពរបស់ប្រជាជាតិក្រោមការជិះជាន់ និងអាណានិគមបរទេស និងការកាន់កាប់ដោយបរទេស ហើយនិងការគោរពអធិបតេយ្យភាពជាតិនិងបូរណភាពទឹកដី និងលើកកម្ពស់វឌ្ឍនភាព និងការអភិវឌ្ឍន៍សង្គម ហើយផលនេះ និងរួមចំនែកដល់ការធ្វើឲ្យសម្រេចបាននូវសមភាពពេញលេញរវាងបុរសនិងស្ត្រី។
- ជឿជាក់ថា ការអភិវឌ្ឍន៍យ៉ាងពេញលេញរបស់ប្រទេសមួយ សុខុមាលភាពរបស់ពិភពលោក និងបុព្វហេតុសន្តិភាព ត្រូវការអោយមានការចូលរួមអោយមានអតិបរិមារបស់ស្ត្រីដោយសមភាពជាមួយបុរសនៅក្នុងវិស័យទាំងអស់។
- ចងចាំថា វិភាគទានដ៏ធំធេងរបស់ស្ត្រីចំពោះសុខុមាលភាពគ្រួសារ និងការអភិវឌ្ឍន៍សង្គមដែលមិនបានទទួលស្គាល់ពេញលេញមកដល់ពេលនេះសារៈសំខាន់សង្គមនៃមាតុភាព និងតួនាទីរបស់ឪពុកម្តាយក្នុងគ្រួសារ និងក្នុងការអប់រំកូន និងដឹងថាតួនាទីរបស់ស្ត្រីក្នុងការបង្កើតកូនមិនគួរជាមូលហេតុនៃការរើសអើងទេ ប៉ុន្តែការអប់រំកូន តម្រូវឲ្យចែករំលែកការទទួលខុសត្រូវរវាងបុរសនិងស្ត្រី និងសង្គមទាំងមូល។
- ដឹងថា តួនាទីជាប្រពៃណីរបស់បុរសនិងស្ត្រីនៅក្នុងសង្គមនិងគ្រួសារ ចាំបាច់ត្រូវមានការផ្លាស់ប្តូរដើម្បីធ្វើឲ្យសម្រេចបាននូវសមភាពពេញលេញរវាងបុរសនិងស្ត្រី។
- ប្តេជ្ញាចិត្ត អនុវត្តគោលការណ៍ទាំងឡាយដែលមានចែងក្នុងសេចក្តីប្រកាសស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ ហើយដើម្បីគោលបំណងនោះ អនុម័តវិធានការចាំបាច់នានាដើម្បីលុបបំបាត់ការរើសអើងគ្រប់ទម្រង់ និងគ្រប់ការសម្តែងចេញ។

# ផ្នែកទី ១

## មាត្រា ១ : និយមន័យនៃការរើសអើង

ដើម្បីបម្រើគោលដៅនៃអនុសញ្ញានេះពាក្យ«ការរើសអើងប្រឆាំងលើស្ត្រីភេទ»សំដៅដល់ការប្រកាន់ ការបែងចែក ការផាត់ចេញ ឬការរឹតត្បិតផ្អែកលើភេទដែលមានអនុភាព ឬមានបំណងធ្វើឲ្យខូចខាត ឬធ្វើឲ្យមោឃៈនូវការទទួលស្គាល់ ការអាស្រ័យផល ឬការប្រើប្រាស់ដោយស្ត្រី ដោយឥតគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រី ផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រីនូវសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាន ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងពលរដ្ឋ ឬក្នុងវិស័យដទៃទៀត។

## មាត្រា ២ : ភាតព្វកិច្ចរបស់រដ្ឋភាគី-វិធានការខាងគោលនយោបាយ ដែលត្រូវអនុវត្តដើម្បីលុបបំបាត់ការរើសអើង

រដ្ឋភាគីផ្តន្ទាទោសការរើងអើងប្រឆាំងនឹងនារីភេទក្នុងគ្រប់ទម្រង់ និងព្រមព្រៀងគ្នាអនុវត្តគោលនយោបាយតាមមធ្យោបាយសមស្រប និងដោយឥតមានការពន្យាពេល ដើម្បីឈានទៅលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ ហើយក្នុងទិសដៅនេះ សន្យាថាៈ

(ក) បញ្ចូលគោលការណ៍សមភាពរវាងបុរសនិងស្ត្រីទៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ជាតិសមស្របឯទៀត ប្រសិនបើមិនទាន់បានបញ្ចូលនៅឡើយ និងធានាតាមផ្លូវច្បាប់ ឬមធ្យោបាយសមស្របដទៃទៀត ដើម្បីធ្វើឲ្យគោលការណ៍នេះ បានសម្រេចជាក់ស្តែង។

(ខ) អនុម័តបទប្បញ្ញត្តិ និងវិធានការច្បាប់ និងវិធានការសមស្របផ្សេងៗរួមមានទណ្ឌកម្មផងដែរ តាមការសមស្រប ដើម្បីហាមឃាត់ការរើងអើងទាំងអស់ប្រឆាំងនឹងនារីភេទ។

(គ) បង្កើតកិច្ចការពារសិទ្ធិរបស់ស្ត្រីតាមផ្លូវច្បាប់ ផ្អែកលើមូលដ្ឋានសមភាពជាមួយបុរស និងធានាការពារប្រកបដោយប្រសិទ្ធិភាពដល់ស្ត្រី ប្រឆាំងនឹងអំពើរើសអើងតាមរយៈសាលាជម្រះក្តីជាតិ ដែលមានសមត្ថកិច្ច និងស្ថាប័នសាធារណៈដទៃទៀត។

(ឃ) ទប់ស្កាត់មិនឲ្យធ្វើអំពើ ឬការអនុវត្តន៍ដែលមានលក្ខណៈរើសអើងប្រឆាំងនឹងស្ត្រីដែលធ្វើឡើងដោយបុគ្គល អង្គការ ឬសហគ្រាសណាមួយ។

(ង) ចាត់វិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រី ដែលធ្វើឡើងដោយបុគ្គល អង្គការ ឬសហគ្រាសណាមួយ។

(ច) ចាត់វិធានការសមស្របទាំងអស់ រួមទាំងការធ្វើច្បាប់ផងដែរ ដើម្បីកែប្រែ ឬដាក់ឲ្យនិរាករណ៍ច្បាប់បទបញ្ជាទម្លាប់ និងការអនុវត្តន៍ណាដែលបង្កើតការរើសអើងប្រឆាំងនឹងនារីភេទ។

(ឆ) ដាក់ឲ្យនិរាករណ៍បទបញ្ញត្តិព្រហ្មទណ្ឌជាតិទាំងឡាយដែលបង្កើតជាការរើសអើងប្រឆាំងនឹងនារីភេទ។

## មាត្រា ៣ : សមភាព-ការធានាអោយមានការប្រើប្រាស់សិទ្ធិ និងសេរីភាពជាមូលដ្ឋាន ដោយសមភាពជាមួយបុរស

ក្នុងគ្រប់វិស័យ ជាពិសេសវិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចម្រើនពេញលេញរបស់ស្ត្រី ដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដោយសមភាពជាមួយបុរស។

## មាត្រា ៤ : វិធានការពិសេសបណ្តោះអាសន្ន

១.ការអនុម័តដោយរដ្ឋភាគីនូវវិធានការពិសេសបណ្តោះអាសន្ន ដើម្បីពន្លឿនការកសាងសមភាពតាមការជាក់ស្តែងរវាងបុរសនិងស្ត្រី មិនត្រូវចាត់ទុកជាការរើសអើងដូចបានចែងក្នុងអនុសញ្ញានេះទេ ប៉ុន្តែទោះតាមបែបណាមួយក៏ដោយមិនត្រូវមានន័យថារក្សាទុកបទដ្ឋានវិសមភាព ឬដាច់ដោយឡែកឡើយ វិធានការទាំងនេះត្រូវដាក់ឲ្យនិរាករណ៍នៅពេលគោលដៅសមភាពនៃឱកាស និងការប្រព្រឹត្តមកលើស្ត្រី បានសម្រេចហើយ។

២.ការអនុម័តដោយរដ្ឋភាគីនូវវិធានការពិសេស រួមទាំងវិធានការទាំងឡាយណា ដែលមានក្នុងអនុសញ្ញានេះ ដើម្បីការពារមាតុភាពផង មិនត្រូវចាត់ទុកជាការរើសអើងឡើយ។

## មាត្រា ៥ : ឥរិយាបថ និងផ្នត់គំនិត

រដ្ឋភាគីត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីៈ

(ក) កែប្រែផ្នត់គំនិត ឥរិយាបថសង្គម និងវប្បធម៌របស់បុរសនិងស្ត្រី ដើម្បីសម្រេចបាននូវការលុបបំបាត់សេចក្តីលំអៀងនិងទម្លាប់ និងការអនុវត្តន៍ជាទម្លាប់ផ្សេងៗទៀត ផ្អែកលើគំនិតស្តីពីភាពទាបជាង ឬខ្ពស់ជាងរបស់ភេទណាមួយ ឬលើតួនាទីជាទម្លាប់សម្រាប់បុរសនិងស្ត្រី។

(ខ) ធានាថាការអប់រំគ្រួសារ មានរាប់បញ្ចូលការយល់ដឹងត្រឹមត្រូវអំពីមាតុភាព ដែលជាមុខងាររបស់សង្គម និងការទទួលស្គាល់ ការទទួលខុសត្រូវរួមរវាងបុរសនិងស្ត្រីក្នុងការចិញ្ចឹមកូន និងការអភិវឌ្ឍន៍របស់កូន ហើយប្រការនេះក៏ត្រូវមាន ការយល់ថាប្រយោជន៍របស់កុមារគឺជាល័ក្ខខ័ណ្ឌចម្បងក្នុងគ្រប់ករណីទាំងអស់។

## មាត្រា ៦ : ការជួញដូរ និងអាជីវកម្មផ្លូវភេទ

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផងដែរ ដើម្បីបង្ក្រាបគ្រប់ទម្រង់នៃការជួញដូរស្ត្រី និងអាជីវកម្មពេស្យាកម្មលើស្ត្រី។

# ផ្នែកទី ២

## មាត្រា ៧ : នយោបាយ និងជីវិតសាធារណៈ

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រីក្នុងជីវភាពនយោបាយ និងសាធារណៈរបស់ប្រទេស និងជាពិសេស ត្រូវធានានូវលក្ខខណ្ឌស្មើភាពរវាងស្ត្រីនិងបុរសនូវសិទ្ធិៈ

(ក) បោះឆ្នោតនៅគ្រប់ការបោះឆ្នោត និងការធ្វើប្រជាមតិសាធារណៈ និងមានសិទ្ធិឈរឈ្មោះបោះឆ្នោតសម្រាប់ស្ថាប័នដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតជាសាធារណៈ។

(ខ) ចូលរួមតាក់តែងគោលនយោបាយរបស់រដ្ឋ និងការអនុវត្តគោលនយោបាយ កាន់មុខការសាធារណៈ និងបំពេញមុខងារសាធារណៈនៅគ្រប់កម្រិតជាន់ថ្នាក់របស់រដ្ឋាភិបាល។

(គ) ចូលរួមក្នុងអង្គការមិនមែនរដ្ឋាភិបាល និងសមាគមន៍ដែលពាក់ព័ន្ធនឹងជីវភាពសាធារណៈ និងនយោបាយរបស់ប្រទេសជាតិ។

## មាត្រា ៨ : ភាពជាតំណាងរបស់រដ្ឋាភិបាល

រដ្ឋភាគីត្រូវប្រកាន់យកវិធានសមស្របទាំងអស់ ដើម្បីធានាឲ្យស្ត្រីមានឱកាស ធ្វើជាតំណាងរដ្ឋាភិបាលថ្នាក់អន្តរជាតិ និងចូលរួមក្នុងកិច្ចការរបស់អង្គការអន្តរជាតិដោយផ្អែកលើល័ក្ខខ័ណ្ឌស្មើភាពជាមួយបុរសនិងដោយគ្មានការរើសអើង។

## មាត្រា ៩ : សញ្ជាតិ

១. រដ្ឋភាគី ត្រូវផ្តល់ឲ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរសក្នុងការទទួលផ្លាស់ប្តូរឬការរក្សាទុកសញ្ជាតិរបស់ខ្លួន។ រដ្ឋភាគី ត្រូវធានាជាពិសេសថា ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬការផ្លាស់ប្តូរសញ្ជាតិរបស់ប្តីក្នុងពេលអាពាហ៍ពិពាហ៍ មិនធ្វើឲ្យផ្លាស់ប្តូរជាស្វ័យប្រវត្តិនូវសញ្ជាតិរបស់ប្រពន្ធមិនធ្វើឲ្យប្រពន្ធគ្មានសញ្ជាតិ ឬបង្ខំឲ្យប្រពន្ធយកសញ្ជាតិរបស់ប្តីឡើយ។

២. រដ្ឋភាគីត្រូវផ្តល់ឲ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរសក្នុងការសម្រេចពីសញ្ជាតិរបស់កូនផងដែរ។

# ផ្នែកទី ៣

## មាត្រា ១០ : ការអប់រំ

រដ្ឋភាគីត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ ដើម្បីធានាឲ្យស្ត្រីមានសិទ្ធិស្មើគ្នានឹងបុរសក្នុងវិស័យអប់រំ និងជាពិសេសដោយ ផ្អែកលើមូលដ្ឋាននៃ

សមភាពរវាងបុរសនិងស្ត្រី ដើម្បីធានាឲ្យស្ត្រីនូវៈ

(ក) លក្ខខណ្ឌដូចគ្នាសម្រាប់មុខរបរ និង ការណែនាំខាងវិជ្ជាជីវៈសម្រាប់ការទទួលបាននូវការសិក្សា និងសម្រាប់ការទទួលបាននូវសញ្ញាប័ត្រក្នុងគ្រឹះស្ថានអប់រំគ្រប់ប្រភេទទាំងនៅជនបទ ទាំងនៅទីក្រុង។ សមភាពនេះត្រូវធានាឲ្យមានក្នុងការអប់រំមុនបឋមសិក្សាការអប់រំចំណេះទូទៅបច្ចេកទេសវិជ្ជាជីវៈ និងបច្ចេកទេសជាន់ខ្ពស់ និងការបណ្តុះបណ្តាលវិជ្ជាជីវៈមធ្យមគ្រប់ផ្នែកផងដែរ។

(ខ) សិទ្ធិទទួលបានកម្មវិធីសិក្សាអប់រំដូចគ្នា ការប្រឡងដូចគ្នា បុគ្គលិកបង្រៀនដែលមានគុណសម្បត្តិដូចគ្នា និងបរិវេណសាលា និងសម្ភារៈសិក្សាដែលមានគុណភាពដូចគ្នា។

(គ) ការលុបបំបាត់រាល់ទស្សនៈជាទម្លាប់ស្តីពីតួនាទីរបស់បុរសនិងស្ត្រីនៅគ្រប់កម្រិត និងគ្រប់ទម្រង់នៃការអប់រំ ដោយលើកទឹកចិត្តដល់ការអប់រំរួមគ្នា និងប្រភេទផ្សេងៗទៀតនៃការអប់រំដែលជួយឲ្យសម្រេចគោលបំណងនេះ និង ជាពិសេសដោយពិនិត្យកែប្រែឡើងវិញនូវសៀវភៅសិក្សា និងកម្មវិធីសិក្សា និងសម្របសម្រួលវិធីសាស្ត្របង្រៀន។

(ឃ) ឱកាសដូចគ្នាក្នុងការទទួលបានអាហារូបករណ៍ និងប្រាក់សម្រាប់ការសិក្សាផ្សេងៗ។

(ង) ឱកាសដូចគ្នាក្នុងការទទួលបានកម្មវិធីអប់រំអចិន្ត្រៃយ៍ រួមមានកម្មវិធីអក្ខរកម្មសម្រាប់នីតិជន និងអនក្ខរជនផង ជាពិសេសកម្មវិធីទាំងឡាយសំដៅកាត់បន្ថយឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាននូវគម្លាតណាមួយក្នុងវិស័យអប់រំដែលមានរវាងបុរសនិងស្ត្រី។

(ច) ការបន្ថយអត្រាបោះបង់ការសិក្សារបស់សិស្សស្រី និងការរៀបចំកម្មវិធីសម្រាប់ក្មេងស្រីនិងស្ត្រី ដែលឆាប់បោះបង់ការសិក្សា។

(ឆ) ឱកាសដូចគ្នាក្នុងការចូលរួមយ៉ាងសកម្មក្នុងកីឡា និងកាយសិក្សា។

(ជ) ការទទួលបានព័ត៌មានអប់រំពិសេសជាក់លាក់ ដើម្បីជួយធានាសុខភាព និងសុខុមាលភាពគ្រួសារ រួមមានព័ត៌មាន និងដំបូន្មានស្តីពីផែនការគ្រួសារផង។

## មាត្រា ១១ : ការងារ

១. រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទក្នុងវិស័យការងារ ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រី ដើម្បីធានានូវសិទ្ធិដូចគ្នា និងជាពិសេសៈ

(ក) សិទ្ធិធ្វើការងារដែលជាសិទ្ធិមិនអាចលក់ដូរ ផ្ទេរ ឬដកហូតបានរបស់មនុស្សជាតិគ្រប់រូប។

(ខ) សិទ្ធិមានឱកាសធ្វើការងារដូចគ្នា រួមទាំងការអនុវត្តលក្ខណៈវិនិច្ឆ័យដូចគ្នាផង ក្នុងការជ្រើសរើសឲ្យធ្វើការងារ។

(គ) សិទ្ធិជ្រើសរើសដោយសេរីនូវវិជ្ជាជីវៈ និងការងារសិទ្ធិឡើងស័ក្តិ សិទ្ធិមានស្ថិរភាពការងារ

ទទួលប្រាក់បំណាច់ និងល័ក្ខខ័ណ្ឌការងារ សិទ្ធិទទួលការបណ្តុះបណ្តាល និងវិក្រិតការខាងវិជ្ជាជីវៈរួមមានការហ្វឹកហាត់ការងារ សុក្រឹតការខាងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជាអចិន្ត្រៃយ៍ផង។

(ឃ) សិទ្ធិក្នុងការទទួលប្រាក់បំណាច់ស្មើគ្នា រួមទាំងផលប្រយោជន៍ និងសិទ្ធិទទួលបានការអនុវត្តន៍ស្មើគ្នាចំពោះការងារដែលមានតម្លៃស្មើគ្នា និងសិទ្ធិទទួលបានការអនុវត្តន៍ស្មើគ្នា លើការវាយតម្លៃគុណភាពការងារ។

(ង) សិទ្ធិទទួលបានសន្តិសុខសង្គម ជាពិសេសប្រយោជន៍សម្រាប់ការចូលនិវត្តន៍ ការគ្មានការងារធ្វើ ការមានជំងឺ ការគ្មានសុពលភាព និងវ័យចំណាស់ ឬបាត់បង់សមត្ថភាពការងារដទៃទៀត ព្រមទាំងសិទ្ធិឈប់សម្រាកដោយមានប្រាក់ឈ្នួល។

(ច) សិទ្ធិទទួលបានការការពារសុខភាព និងសុវត្ថិភាពក្នុងល័ក្ខខ័ណ្ឌការងារ រួមមានការការពារមុខងារបន្តពូជផង។

២. ដើម្បីបង្ការការរើសអើងប្រឆាំងនឹងស្ត្រីផ្អែកលើអាពាហ៍ពិពាហ៍ ឬមាតុភាព និងដើម្បីធានាសិទ្ធិធ្វើការងាររបស់ស្ត្រីឲ្យមានប្រសិទ្ធិភាព រដ្ឋភាគីសន្យាចាត់វិធានការសមស្របដើម្បីៈ

(ក) ហាមឃាត់ដោយដាក់ទណ្ឌកម្មនូវការបណ្តេញចេញពីការងារ ដោយមូលហេតុមានគភ៌ ឬការឈប់សម្រាកមាតុភាព និងការរើសអើងក្នុងការបណ្តេញចេញពីការងារដោយផ្អែកលើស្ថានភាពអាពាហ៍ពិពាហ៍។

(ខ) ផ្តល់ការឈប់សម្រាកមាតុភាពដោយមានប្រាក់ឈ្នួល ឬប្រាក់បំណាច់សង្គមកិច្ចស្មើគ្នាដោយគ្មានការបាត់បង់ការងារ អតីតភាពការងារ ឬជំនួយសង្គមកិច្ច។

(គ) ជំរុញការផ្តល់សេវាគាំពារសង្គមកិច្ចចាំបាច់ ដើម្បីឲ្យឪពុកម្តាយអាចបញ្ចូលកាតព្វកិច្ចគ្រួសារជាមួយនិងការទទួលខុសត្រូវតាមវិជ្ជាជីវៈ និងការចូលរួមក្នុងជីវភាពសាធារណៈជាពិសេសដោយសម្រួលដល់ការបង្កើត និងការអភិវឌ្ឍន៍បណ្តាញនៃសម្ភារៈរូបវន្តសំរាប់ថែទាំកុមារ។

(ឃ) ផ្តល់ការការពារពិសេសដល់ស្ត្រីកំពុងមានគភ៌ពីប្រភេទការងារទាំងឡាយណាដែលបង្ហាញឲ្យឃើញថាមានគ្រោះថ្នាក់ដល់ពួកគេ។

៣. ច្បាប់ការពារស្ត្រីទាក់ទងនឹងបញ្ហាដែលបានចែងក្នុងមាត្រានេះ ត្រូវលើកយកមកពិនិត្យឡើងវិញជាទៀងទាត់ទៅតាមចំនេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេស និងត្រូវសើរើធ្វើនិរាករណ៍ ឬអនុវត្តន៍បន្តទៅតាមការចាំបាច់។

## មាត្រា ១២ : ការថែទាំសុខភាព

១. រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីក្នុងវិស័យថែទាំងសុខភាព ដើម្បីធានាដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រីនូវសិទ្ធិទទួលសេវាថែទាំសុខភាព រួមទាំងមធ្យោបាយទាក់ទងនឹងផែនការគ្រួសារផង។

២. ក្រៅពីបទប្បញ្ញត្តិដែលចែងក្នុងកថាខណ្ឌ១នៃមាត្រានេះរដ្ឋភាគីត្រូវធានាចំពោះស្ត្រីកំពុងមានគភ៌ កំពុងសម្រាលកូន និងក្រោយពេលសម្រាលកូននូវការផ្តល់សេវាសមស្រប បើចាំបាច់ដោយឥតគិតថ្លៃ ព្រមទាំងអាហាររូបត្ថម្ភគ្រប់គ្រាន់ក្នុងរយៈពេលមានគភ៌ និងពេលបំបៅកូន។

## មាត្រា ១៣ : សេដ្ឋកិច្ច និងអត្ថប្រយោជន៍ផ្នែកសង្គម

រដ្ឋភាគី ត្រូវចាត់វិធានការសមស្របនានា ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីក្នុងវិស័យជីវភាពសេដ្ឋកិច្ច និងសង្គមកិច្ចផ្សេងទៀត ដើម្បីធានាដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រីនូវសិទ្ធិដូចគ្នា ជាពិសេសៈ

(ក) សិទ្ធិទទួលបានផលប្រយោជន៍សម្រាប់គ្រួសារ

(ខ) សិទ្ធិខ្ចីប្រាក់ពីធនាគារ អ៊ីប៉ូតែក និងទម្រង់ផ្សេងៗទៀតនៃឥណទានហិរញ្ញវត្ថុ

(គ) សិទ្ធិចូលរួមក្នុងសកម្មភាពកំសាន្ត កីឡា និងគ្រប់ទិដ្ឋភាពនៃជីវភាពវប្បធម៌។

## មាត្រា ១៤ : ស្ត្រីជនបទ

១. រដ្ឋភាគី ត្រូវគិតគូរដល់បញ្ហាពិសេសដែលស្ត្រីនៅជនបទប្រឈម និងតួនាទីសំខាន់របស់ស្ត្រីជនបទក្នុងការរក្សាភាពគង់វង្សសេដ្ឋកិច្ចគ្រួសាររបស់ខ្លួន រួមមានការងាររបស់ពួកគេក្នុងផ្នែកគ្មានចំណូលសេដ្ឋកិច្ចផង។ រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីធានាការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះចំពោះស្ត្រីនៅជនបទ។

២. រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីនៅជនបទ ដើម្បីធានានូវការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍជនបទ និងទទួលអត្ថប្រយោជ៍ពីការអភិវឌ្ឍន៍ជនបទដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រី និងពិសេសត្រូវធានាឲ្យស្ត្រីជនបទទាំងនោះនូវសិទ្ធិៈ

(ក) ចូលរួមពេញលេញក្នុងការតាក់តែង និងអនុវត្តផែនការអភិវឌ្ឍន៍នៅគ្រប់លំដាប់ថ្នាក់។

(ខ) មានសិទ្ធិទទួលបានសេវាគ្រប់គ្រាន់ខាងវិស័យសុខាភិបាល រួមទាំងព័ត៌មាន ការប្រឹក្សា និងសេវាផែនការគ្រួសារ។

(គ) ទទួលអត្ថប្រយោជន៍ដោយផ្ទាល់ពីកម្មវិធីសន្តិសុខសង្គម។

(ឃ) ទទួលបានការបណ្តុះបណ្តាល និងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធគ្រប់ប្រភេទរួមទាំងការអប់រំទាក់ទងនឹងអក្ខរកម្មបង្កើតមុខរបរផង ព្រមទាំងជាពិសេសអត្ថប្រយោជន៍សេវាសហគមន៍ និងការពង្រីកសេវាផ្សេងៗទៀត ដើម្បីបង្កើនសមត្ថភាពបច្ចេកទេសរបស់ស្ត្រី។

(ង) រៀបចំក្រុមជួយខ្លួនឯង និងសហករណ៍ ដើម្បីទទួលបានឱកាសផ្នែកសេដ្ឋកិច្ចស្មើគ្នាតាមរយៈការងារមានប្រាក់ឈ្នួល ឬការងារឯករាជ្យ។

(ច) ចូលរួមក្នុងគ្រប់សកម្មភាពរបស់សហគមន៍

(ឆ) មានសិទ្ធិទទួលបានឥណទាន និងប្រាក់កម្ចីខាងកសិកម្ម សេវារកទីផ្សារ បច្ចេកវិជ្ជាសមស្រប និងការគិតគូស្មើគ្នាក្នុងការកែទម្រង់ដីធ្លី និងកសិកម្ម ព្រមទាំងក្នុងគម្រោងបែងចែកដីធ្លី។

(ជ) អាស្រ័យផលល័ក្ខខ័ណ្ឌរស់នៅគ្រប់គ្រាន់ ជាពិសេសទាក់ទងនឹងការមានផ្ទះសម្បែង អានាម័យ ការផ្គត់ផ្គង់អគ្គិសនី និងទឹក ការដឹកជញ្ជូន និងទូរគមនាគមន៍។

## ផ្នែកទី ៤

### មាត្រា ១៥ : សិទ្ធិស្មើគ្នាចំពោះមុខច្បាប់

១. រដ្ឋភាគីត្រូវផ្តល់ឲ្យស្ត្រីនូវសមភាពជាមួយបុរសនៅចំពោះមុខច្បាប់។

២. រដ្ឋភាគី ត្រូវផ្តល់អោយស្ត្រីក្នុងរឿងរដ្ឋប្បវេណី ត្រូវផ្តល់ឲ្យស្ត្រីនូវឋានៈនីត្យានុកូលដូចគ្នានឹងបុរស និងមានឱកាសដូចគ្នាដើម្បីប្រើប្រាស់ឋានៈនេះ។ ជាពិសេសរដ្ឋភាគីត្រូវផ្តល់ឲ្យស្ត្រីនូវសិទ្ធិស្មើគ្នាក្នុងការចុះកិច្ចសន្យា និងការគ្រប់គ្រងទ្រព្យ និងត្រូវឲ្យមានការប្រព្រឹត្តមកលើស្ត្រីដូចគ្នាក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ និងសាលាជំរះក្តី។

៣. រដ្ឋភាគីព្រមព្រៀងគ្នាថា កិច្ចសន្យាទាំងអស់ និងលិខិតុបករណ៍ឯកជនគ្រប់ប្រភេទដែលមានអានុភាពនីត្យានុកូល សំដៅរឹតត្បិតឋានៈនីត្យានុកូលរបស់ស្ត្រី ត្រូវទុកជាមោឃៈ។

៤. រដ្ឋភាគី ត្រូវឲ្យបុរស និងស្ត្រីមានសិទ្ធិដូចគ្នាចំពោះមុខច្បាប់ ដែលទាក់ទងដល់សិទ្ធិដើរហើររបស់បុគ្គល និងសេរីភាពជ្រើសរើសនិវេសនដ្ឋាន និងលំនៅដ្ឋាន។

### មាត្រា ១៦ : អាពាហ៍ពិពាហ៍ និងគ្រួសារ

១. រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីលើរាល់បញ្ហាដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ និងជាពិសេសដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី ត្រូវធានាឲ្យស្ត្រីនូវៈ

(ក) សិទ្ធិដូចគ្នាក្នុងការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍។

(ខ) សិទ្ធិដូចគ្នាក្នុងការជ្រើសរើសសហព័ទ្ធរបស់ខ្លួនដោយសេរី និងក្នុងការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តែនៅពេលណាដែលពួកគេព្រមព្រៀងគ្នាដោយសេរី និងដោយពេញលេញប៉ុណ្ណោះ។

(គ) សិទ្ធិនិងការទទួលខុសត្រូវដូចគ្នានៅពេលមានចំណងអាពាហ៍ពិពាហ៍ និង នៅពេលរំលាយអាពាហ៍ពិពាហ៍។

(ឃ) សិទ្ធិនិងការទទួលខុសត្រូវដូចគ្នាក្នុងតួនាទីជាឪពុកម្តាយលើបញ្ហាទាក់ទង និងកូនដោយឥតគិតពីស្ថានភាពគ្រួសារ ហើយអត្ថប្រយោជន៍របស់កូនត្រូវស្ថិតជាចម្បងលើគ្រប់ករណីទាំងអស់។

(ង) សិទ្ធិដូចគ្នាក្នុងការសម្រេចចិត្តដោយសេរី និងដោយស្មារតីទទួលខុសត្រូវក្នុងការសម្រេចអំពី

ចំនួនកូន និងការពន្យាកំណើត និងក្នុងការទទួលបានព័ត៌មាន ការអប់រំ និងមធ្យោបាយដើម្បីឲ្យស្ត្រីអាចប្រើប្រាស់សិទ្ធិទាំងនេះ។

(ច) សិទ្ធិនិងការទទួលខុសត្រូវដូចគ្នាចំពោះភាពជាអាណាព្យាបាលការការពារការគ្រប់គ្រង និងការទទួលចិញ្ចឹមកូនអ្នកដទៃ ឬក្នុងការអនុវត្តស្រដៀងគ្នានេះ បើគំនិតទាំងនេះ មានស្រាប់នៅក្នុងច្បាប់ជាតិ។ នៅគ្រប់ករណីទាំងអស់ អត្ថប្រយោជន៍របស់កូន ត្រូវចាត់ទុកជាចម្បង។

(ឆ) សិទ្ធិបុគ្គលដូចគ្នារវាងប្តីនិងប្រពន្ធរួមមានសិទ្ធិជ្រើសរើសនាមត្រកូលវិជ្ជាជីវៈ និងមុខរបរផងដែរ។

(ជ) សិទ្ធិដូចគ្នាសម្រាប់ទាំងពីរនាក់ប្តីនិងប្រពន្ធចំពោះកម្មសិទ្ធិ ការទិញ ការចាត់ចែង ការគ្រប់គ្រង ការអាស្រ័យផល និងការប្រគល់ទ្រព្យសម្បត្តិ ទោះមិនគិតថ្លៃក្តី ឬគិតថ្លៃក្តី។

២. ការភ្ជាប់ពាក្យ និងការរៀបអាពាហ៍ពិពាហ៍កូន ដែលមិនទាន់គ្រប់អាយុរៀបការមិនត្រូវមានអានុភាពផ្លូវច្បាប់ទេ ហើយគេត្រូវចាត់វិធានការចាំបាច់ទាំងអស់ រួមទាំងការធ្វើច្បាប់ផង ដើម្បីកំណត់អាយុអប្បបរមាសម្រាប់រៀបអាពាហ៍ពិពាហ៍ ហើយចាំបាច់ត្រូវចុះបញ្ជីអាពាហ៍ពិពាហ៍នៅក្នុងបញ្ជីផ្លូវការ។

## ផ្នែកទី ៥

### មាត្រា ១៧: គណៈកម្មាធិការ

១. ក្នុងគោលបំណងពិនិត្យការវិវឌ្ឍន៍ទៅមុខនៃការអនុវត្តន៍អនុសញ្ញានេះ គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទមួយត្រូវបានបង្កើតឡើងចាប់ពីនេះទៅត្រូវប្រើត្រឹមតែ (គណៈកម្មាធិការ) គណៈកម្មាធិការនេះមានអ្នកជំនាញការ ១៨រូប នៅពេលដែលអនុសញ្ញានេះចូលជាធរមាន។បន្ទាប់ពីរដ្ឋភាគី ៣៥ បានផ្តល់សច្ចាប័ន ឬបានចូលជាសមាជិកនៃអនុសញ្ញានេះ គណៈកម្មាធិការនេះនឹងមានអ្នកជំនាញការចំនួន ២៣រូប ដែលមានសិលធម៌ និងមានសមត្ថកិច្ចខ្ពស់ក្នុងវិស័យដែលត្រូវអនុវត្តអនុសញ្ញានេះ។ អ្នកជំនាញការត្រូវបោះឆ្នោតជ្រើសរើសដោយរដ្ឋភាគីក្នុងចំណោមជនជាតិរបស់ខ្លួន និងត្រូវធ្វើការក្នុងឋានៈជាបុគ្គលឯកជន ដោយពិចារណាបែងចែងទៅតាមភូមិសាស្ត្រដោយសមធម៌ និងឲ្យមានតំណាងផ្សេងៗនៃអារ្យធម៌ ព្រមទាំងទៅតាមប្រព័ន្ធច្បាប់ធំៗផង។

២. សមាជិករបស់គណៈកម្មាធិការ ត្រូវជ្រើសរើសតាមរយៈការបោះឆ្នោតសម្ងាត់ពីបញ្ជីបេក្ខជនដែលស្នើដោយរដ្ឋភាគី។ រដ្ឋភាគីនីមួយៗអាចដាក់ស្នើ បេក្ខជនម្នាក់ក្នុងចំណោមបេក្ខជនជាតិរបស់ខ្លួន។

៣. ការបោះឆ្នោតដំបូងបង្អស់ធ្វើឡើង ៦ខែ ក្រោយពីកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ។ យ៉ាងតិច ៣ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗអគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវចេញលិខិតអញ្ជើញរដ្ឋភាគីអោយដាក់ស្នើនាមបេក្ខជនរបស់ខ្លួនរយៈពេល ២ខែ។ អគ្គលេខាធិការត្រូវរៀបចំតាមលំដាប់អក្ខរក្រមនូវបញ្ជីឈ្មោះបេក្ខជនដែលស្នើដោយរដ្ឋភាគីដោយបញ្ជាក់ឈ្មោះរដ្ឋភាគីដែលបានជ្រើសតាំងបេក្ខជនទាំងនោះ ហើយផ្ញើបញ្ជីនេះទៅគ្រប់រដ្ឋភាគី។

៤. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការត្រូវធ្វើឡើងក្នុងសម័យប្រជុំរបស់រដ្ឋភាគីតាមការកោះអញ្ជើញដោយអគ្គលេខាធិការនៅទីស្នាក់ការអង្គការសហប្រជាជាតិ។កូរ៉ុមសំរាប់កិច្ចប្រជុំគឺពីរភាគបីនៃរដ្ឋភាគី។ បេក្ខជនដែលជាប់ជាសមាជិកគណៈកម្មាធិការត្រូវតែជាបេក្ខជនទទួលបានសំលេងច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាតពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាននិងបានបោះឆ្នោត។

៥. សមាជិកគណៈកម្មាធិការត្រូវជ្រើសរើសតាមរយៈការបោះឆ្នោតសម្រាប់រយៈពេល ៤ឆ្នាំ។ ប៉ុន្តែអាណត្តិសមាជិក ៩ រូបដែលជាប់នៅពេលបោះឆ្នោតលើកទីមួយត្រូវផុតកំណត់រយៈពេលពីរឆ្នាំហើយឈ្មោះសមាជិកទាំង ៩រូបនេះត្រូវចាប់ឆ្នោតជ្រើសរើសដោយប្រធានអង្គប្រជុំភ្លាមៗបន្ទាប់ពីការបោះឆ្នោតលើកទី១។

៦. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការបន្ថែម៥រូប នឹងត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិច្បាប់ក្នុងកថាខ័ណ្ឌ២ កថាខ័ណ្ឌ៣ និងកថាខ័ណ្ឌ៤នៃមាត្រានេះបន្ទាប់ពីមានការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកលើកទី៣៥។ អាណត្តិសមាជិក ២រូប នៃសមាជិកបន្ថែមដែលបានជាប់ឆ្នោតនឹងត្រូវផុតកំណត់រយៈពេល២ឆ្នាំ ហើយឈ្មោះសមាជិកទាំង២រូបនេះ ត្រូវជ្រើសរើសតាមការចាប់ឆ្នោតដោយប្រធានគណៈកម្មាធិការ។

៧. ដើម្បីបំពេញកន្លែងទំនេរដោយចៃដន្យ រដ្ឋភាគីណាដែលមានជំនាញការរបស់ខ្លួនឈប់បំពេញមុខងារសមាជិកគណៈកម្មាធិការ ត្រូវតែងតាំងអ្នកជំនាញការម្នាក់ទៀតពីចំណោមជនជាតិរបស់ខ្លួន ដោយមានការយល់ព្រមពីគណៈកម្មាធិការ។

៨. សមាជិកគណៈកម្មាធិការត្រូវទទួលថវិកាពីធនធានអង្គការសហប្រជាជាតិតាមចំនែកនិងល័ក្ខខ័ណ្ឌដែលកំណត់ដោយមហាសន្និបាត អាស្រ័យលើសារៈសំខាន់នៃការងាររបស់គណៈកម្មាធិការ។

៩. អគ្គលេខាអង្គការសហប្រជាជាតិត្រូវផ្តល់បុគ្គលិកនិងសម្ភារៈរូបវ័ន្តដែលចាំបាច់សម្រាប់គណៈកម្មាធិការបំពេញមុខងារឲ្យមានប្រសិទ្ធិភាព ស្របតាមអនុសញ្ញានេះ។

## មាត្រា ១៨: ការរាយការណ៍ដោយរដ្ឋភាគី

១. រដ្ឋភាគីសន្យាដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីគណៈកម្មាធិការពិនិត្យនូវរបាយការស្តីពីវិធានការខាងនីតិកម្ម តុលារ រដ្ឋបាល វិធានការផ្សេងៗដែលបានអនុម័តផ្តល់អានុភាពដល់បទប្បញ្ញត្តិនៃអនុសញ្ញានេះ ព្រមទាំងការរីកចម្រើនដែលសម្រេចបានៈ

(ក) ក្នុងរយៈពេល ១ឆ្នាំ ក្រោយពីការចូលជាធរមាននៃអនុសញ្ញាចំពោះរដ្ឋដែលពាក់ព័ន្ធ។

(ខ) បន្ទាប់មក យ៉ាងហោចណាស់រៀងរាល់ ៤ឆ្នាំម្តង និងរបាយការណ៍បន្ថែមបើមានសេចក្តីស្នើសុំរបស់គណៈកម្មាធិការ។

២. របាយការណ៍អាចបញ្ជាក់ពីកត្តា និងការលំបាកដែលនាំអោយប៉ះពាល់ដល់ការបំពេញកាតព្វកិច្ចស្របតាមអនុសញ្ញានេះ។

## មាត្រា ១៩: បទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការ

១. គណៈកម្មាធិការត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

២. គណៈកម្មាធិការត្រូវបោះឆ្នោតជ្រើសរើសមន្ត្រីការិយាល័យខ្លួនសំរាប់រយៈពេល ២ឆ្នាំ។

## មាត្រា ២០: ការប្រជុំប្រចាំឆ្នាំ

១. គណៈកម្មាធិការត្រូវជួបប្រជុំជាធម្មតាមិនលើសពី ២សប្តាហ៍ក្នុង១ឆ្នាំៗ ដើម្បីពិនិត្យរបាយការណ៍ដែលស្នើឡើងស្របតាមមាត្រា ១៨នៃអនុសញ្ញានេះ។

២. សម័យប្រជុំគណៈកម្មាធិការត្រូវប្រារព្ធធ្វើជាធម្មតា នៅទីស្នាក់ការនៃអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របមួយផ្សេងពីនេះ អាស្រ័យដោយការកំណត់របស់គណៈកម្មាធិការ។

## មាត្រា ២១: អនុសាសន៍នានាដោយគណៈកម្មាធិការ

១. តាមរយៈក្រុមព្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំជូនមហាសន្និបាតនៃអង្គការសហប្រជាជាតិអំពីសកម្មភាពរបស់ខ្លួន និង អាចផ្តល់យោបល់និងផ្តល់អនុសាសន៍ទូទៅដោយផ្អែកលើការពិនិត្យរបាយការណ៍ និងព័ត៌មានដែលទទួលបានពីរដ្ឋភាគី។ ការផ្តល់យោបល់និងផ្តល់អនុសាសន៍ ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍របស់គណៈកម្មាធិការអមដោយមូលវិចារណ៍របស់រដ្ឋភាគី ប្រសិនបើមាន។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបញ្ជូនរបាយការណ៍របស់គណៈកម្មាធិការទៅគណៈកម្មាការទទួលបន្ទុកស្ថានភាពស្ត្រី ដើម្បីជ្រាបជាព័ត៌មាន។

## មាត្រា ២២: ការរាយការណ៍ដោយអង្គការឯកទេស

ភ្នាក់ងារឯកទេស មានសិទ្ធិធ្វើជាតំណាងនៅពេលពិនិត្យការអនុវត្តន៍បទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលស្ថិតក្នុងក្របខ័ណ្ឌសកម្មភាពរបស់ខ្លួន។ គណៈកម្មាធិការអាចអញ្ជើញភ្នាក់ងារឯកទេសនានាឲ្យដាក់របាយការណ៍ស្តីពីការអនុវត្តន៍អនុសញ្ញានេះក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន។

# ផ្នែកទី ៦

## មាត្រា ២៣: ការដាក់ជំនួយដោយច្បាប់

គ្មានចំនុចណាមួយក្នុងអនុសញ្ញានេះ ធ្វើឲ្យប៉ះពាល់ដល់បទប្បញ្ញត្តិដែលនាំឲ្យសម្រេចបាននូវសមភាពរវាងបុរសនិងស្ត្រី ដែលអាចមានច្រើនជាងនេះ នៅក្នុង:

(ក) ច្បាប់របស់រដ្ឋភាគី ឬ

(ខ) អនុសញ្ញា សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតដែលនៅជាធរមានក្នុងរដ្ឋនោះ។

## មាត្រា ២៤: រដ្ឋភាគីត្រូវតែអនុវត្ត

រដ្ឋភាគីសន្យាអនុម័តគ្រប់វិធានការចាំបាច់នៅថ្នាក់ជាតិដើម្បីធ្វើឲ្យសម្រេចបាននូវការប្រើប្រាស់ឲ្យបានពេញលេញនូវសិទ្ធិទាំងឡាយណាដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ។

## មាត្រា ២៥: ការចូលរួមជាសមាជិកហត្ថលេខី

១. អនុសញ្ញានេះត្រូវបើកចំហឲ្យរដ្ឋទាំងអស់ចុះហត្ថលេខា។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវចាត់តាំងជាអ្នកទទួលតម្កល់ទុកអនុសញ្ញានេះ។

៣. អនុសញ្ញានេះជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន។ លិខិតតុបករណ៍នៃការផ្តល់សច្ចាប័នត្រូវតម្កល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៤. អនុសញ្ញានេះត្រូវបើកចំហឲ្យរដ្ឋទាំងអស់សុំចូលជាសមាជិក។ ការសុំចូលជាសមាជិកត្រូវធ្វើឡើងដោយការតម្កល់លិខិតតុបករណ៍សុំចូលជាសមាជិកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា ២៦: ការសើរើអនុសញ្ញា ស៊ីដ

១. រដ្ឋភាគីអាចសុំសើរើអនុសញ្ញានេះបានគ្រប់ពេលវេលាដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២. មហាសន្និបាតអង្គការសហប្រជាជាតិត្រូវសម្រេចលើវិធានការដែលត្រូវចាត់ ប្រសិនជាមានតាមសេចក្តីស្នើសុំនោះ។

## មាត្រា ២៧: កាលបរិច្ឆេទចូលជាធរមាន

១. អនុសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទី៣០ ក្រោយកាលបរិច្ឆេទនៃការតម្កល់លិខិតតុបករណ៍ផ្តល់សច្ចាប័ន ឬការសុំចូលជាសមាជិកទី២០ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២. សម្រាប់រដ្ឋនីមួយៗដែលផ្តល់សច្ចាប័នលើអនុសញ្ញនេះ ឬសុំចូលជាសមាជិកក្រោយពីការតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការសុំចូលជាសមាជិកទី២០ អនុសញ្ញានេះនឹងត្រូវចូលជាធរមាននៅថ្ងៃទី៣០ ក្រោយកាលបរិច្ឆេទនៃការដាក់លិខិតតុបករណ៍ផ្តល់សច្ចាប័ន ឬការសុំចូលជាសមាជិករបស់ខ្លួន។

## មាត្រា ២៨: ខរក្សាទុក

១. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវទទួល និងផ្សព្វផ្សាយដល់រដ្ឋទាំងអស់នូវអត្ថបទ

ខរក្សាទុកដែលរដ្ឋបានធ្វើនៅពេលផ្តល់សច្ចាប័ន ឬសុំចូលជាសមាជិក។

២. ខរក្សាទុកដែលមិនស្របតាមកម្មវត្ថុនិងគោលបំណងនៃអនុសញ្ញានេះ មិនត្រូវបានអនុម័តអោយធ្វើឡើយ។

៣. ខរក្សាទុកទាំងឡាយដែលអាចដកចេញទៅវិញបានគ្រប់ពេលវេលា ដោយការជូនដំណឹងទៅដល់អគ្គលេខាធិការអង្គការសហប្រជាជាតិដែលត្រូវជូនដំណឹងនេះបន្តដល់រដ្ឋទាំងអស់។ ការជូនដំណឹងជាលាយល័ក្ខណ៍អក្សរត្រូវមានប្រសិទ្ធភាពនៅថ្ងៃដែលបានទទួល។

## មាត្រា ២៩: ការសម្រេចនៃអជ្ញាកណ្តាល

១. រាល់វិវាទរវាងរដ្ឋភាគីពីរ ឬច្រើនជាងនេះដែលពាក់ព័ន្ធនិងការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ ដែលមិនអាចដោះស្រាយតាមរយៈការចរចាបាន ត្រូវដាក់ឲ្យមានការសម្រេចដោយអាជ្ញាកណ្តាលតាមសំណើរបស់ភាគីណាមួយនៃគូវិវាទនេះ។ បើក្នុងរយៈពេល ៦ខែ គិតចាប់ពីថ្ងៃស្នើអោយមានអាជ្ញាកណ្តាល ភាគីវិវាទមិនឯកភាពលើការរៀបចំអាជ្ញាកណ្តាលទេ ភាគីណាមួយនៃភាគីវិវាទទាំងនោះអាចលើករឿងវិវាទទៅតុលាការយុត្តិធម៌អន្តរជាតិ តាមសេចក្តីស្នើសុំ ស្របតាមលក្ខន្តិកៈរបស់តុលាការ។

២. រដ្ឋភាគីនីមួយៗ នៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័ន ឬសុំចូលជាសមាជិកនៃអនុសញ្ញានេះ អាចប្រកាសថា ខ្លួនមិនជាប់កាតព្វកិច្ចនឹងកថាខណ្ឌ១ នៃមាត្រានេះទេ។ រដ្ឋភាគីឯទៀតនឹងមិនជាប់កាតព្វកិច្ចក្នុងកថាខណ្ឌ១ នេះ ជាមួយរដ្ឋភាគីណាដែលមាន ខរក្សាទុកនេះឡើយ។

៣. រដ្ឋភាគីណាដែលមាន ខរក្សាទុកស្របតាមកថាខណ្ឌ២ នៃមាត្រានេះ អាចដក ខរក្សាទុករបស់ខ្លួនវិញគ្រប់ពេល ដោយការជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា ៣០: ភាសាផ្លូវការនៃឯកសារ

អនុសញ្ញានេះដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតំលៃស្មើគ្នា និងតម្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

ជាបន្ទាល់នៃអនុសញ្ញានេះ បុណ្ណទូតដែលមានហត្ថលេខាខាងក្រោម ហើយដែលបានទទួលនូវការអនុញ្ញាតយ៉ាងត្រឹមត្រូវ បានចុះហត្ថលេខាលើអនុសញ្ញានេះ។